# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២៤ សសរ

## សេចក្តីសម្រេច

ស្តីពី

**ការបង្កើតក្រុមការងារស្រាវជ្រាវផ្តល់យោបល់ផ្នែកអភិបាលកិច្ចសន្តិសុខ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៧២៧៨ អបព.កបទ.សអ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារស្រាវជ្រាវផ្តល់យោបល់ផ្នែកអភិបាលកិច្ចសន្តិសុខ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | ប្រធាន |
| ២. ឯកឧត្តម **ហ៊ុន ម៉ាណែត** | នាយឧត្តមសេនីយ៍ និងជាមេបញ្ជាការរងកងទ័ពជើងគោក | អនុប្រធាន |
| ៣. ឯកឧត្តម **វង្សី វិស្សុត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯកឧត្តម **កើត រិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៥. លោកជំទាវ **អ៊ិត សោភា** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិកា |



www.pheakdeylaw.com

| | | |
|---|---|---|
| ៦. ឯកឧត្តម ហ៊ុន ម៉ានិត | អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច នៃក្រសួងការពារជាតិ | សមាជិក |
| ៧. ឯកឧត្តម គង់ មិចុល | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៨. ឯកឧត្តម គុណ ញឹម | អគ្គនាយកគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ៩. ឯកឧត្តម ឌី វិជ្ជា | ប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ នៃក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ២ ._**

ក្រុមការងារនេះមានភារកិច្ច សិក្សាស្រាវជ្រាវ និងផ្ដល់យោបល់ផ្នែកអភិបាលកិច្ច សន្តិសុខផ្ទៃក្នុងប្រទេស ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធនៅក្នុងស្រុក និងនៅបរទេស ដើម្បីផ្សព្វផ្សាយព័ត៌មានត្រឹមត្រូវ និងរៀបចំអនុសាសន៍ស្ដីពីវិធានការចាំបាច់ និងគោលនយោបាយការពារសន្តិសុខសណ្ដាប់ធ្នាប់សង្គម ទ្រព្យសម្បត្តិសាធារណៈ និងគម្រោងអភិវឌ្ឍន៍ជាតិសំខាន់ៗ ។

ក្រុមការងារនេះ អាចស្នើបន្ថែមសមាសភាព និងអញ្ជើញតំណាងក្រសួង-ស្ថាប័ន វិស័យឯកជន ឥស្សរជនជាតិ-អន្តរជាតិ ឬ ភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីប្រជុំពិគ្រោះយោបល់ ឬ ចូលរួមក្នុងការងារសិក្សាស្រាវជ្រាវ និងផ្ដល់យោបល់ តាមការចាំបាច់ ។

**ប្រការ៣ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com